**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាជាមួយនិស្សិតសន្តយ៉ូស្វ៊ីននៅភ្នំពេញ**
**ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៨**
*តើព្រះជាម្ចាស់បានប្រទានអ្វីខ្លះឲ្យខ្ញុំ?*

អត្ថបទទី១៖ ២ពង្សា ២,១.៦-១៤
ដំណឹងល្អ៖ មក ៦,១-៦.១៦-១៨

បងប្អូនជាទីស្រឡាញ់!

នៅថ្ងៃអត្ថបទដែលយើងបានស្តាប់ ព្រះយេស៊ូបានបន្តទេសនាដើម្បីណែនាំឲ្យយើងរៀបចំចិត្តគំនិត ដើម្បីបង្កើតព្រះរាជ្យរបស់ព្រះជាម្ចាស់។ ព្រះយេស៊ូនិយាយ២០០០ឆ្នាំមុន ឲ្យយើងបន្តអនុវត្តនៅក្នុងជីវិតរបស់យើងផ្ទាល់ ព្រះយេស៊ូមានព្រះបន្ទូលមួយដើម្បីណែនាំឲ្យយើងដឹងថា ជីវិតរបស់យើងត្រូវតែទីពឹងលើព្រះជាម្ចាស់ដែលជាព្រះបិតា ដែលថែរក្សាយើង ស្រឡាញ់យើង យកចិត្តទុកដាក់នឹងយើង ហើយយើងត្រូវតែមើលអ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានបង្កើត។ នៅទីនេះ ជាឱកាសមួយដើម្បីនឹកឃើញដល់ធម្មជាតិ ក្នុងជីវិតរបស់យើងជួនកាលយើងរវីរវល់និងរឿងដែលមិនសំខាន់។ ឲ្យយើងរវីរវល់នឹងអ្វីដែលណែនាំឲ្យជីវិតរបស់យើងរកឃើញសេចក្តីសុខ យើងអាចរកឃើញសេចក្តីសុខ ប្រសិនបើយើងចេះរស់នៅដោយទទួលស្គាល់អំពីអ្វីៗទាំងអស់ដែលព្រះជាម្ចាស់ប្រទានឲ្យយើង។ ប្រសិនបើ យើងដឹងថាជីវិតរបស់យើងត្រូវតែស្រឡាញ់ព្រះជាម្ចាស់ និងស្រឡាញ់បងប្អូនឯទៀតៗ អ្វីៗទាំងអស់ដែលយើងធ្វើពីមួយថ្ងៃទៅមួយថ្ងៃអាចមានតម្លៃថ្មី អត្ថន័យថ្មី។ ទោះបីយើងមានការងារ យើងមានផែនការសម្រាប់អនាគតមែន ប៉ុន្តែអ្វីដែលសំខាន់ឲ្យយើងនឹកឃើញ **តើព្រះជាម្ចាស់បានប្រទានអ្វីខ្លះឲ្យខ្ញុំ?** ជីវិត សេចក្តីស្រឡាញ់ តើខ្ញុំធ្វើយ៉ាងណាដើម្បីឲ្យជីវិត និងសេចក្តីស្រឡាញ់នេះ មានតម្លៃសម្រាប់ខ្ញុំនិងសម្រាប់បងប្អូនឯទៀតៗ។

សព្វថ្ងៃមនុស្សយើង រស់នៅក្នុងសង្គមដែលកំពុងអភិវឌ្ឍន៍ ណែនាំឲ្យមនុស្សចង់ភ័យខ្លះៗដែរ ការអភិវឌ្ឍន៍មានផលប្រយោជន៍ច្រើនសម្រាប់មនុស្ស ការអភិវឌ្ឍន៍ជួយឲ្យយើងមានសេចក្តីសុខ ប៉ុន្តែសំខាន់គឺចិត្តគំនិតរបស់យើង។ តើចិត្តគំនិតរបស់យើងរកឃើញសេចក្តីសុខមែនឬទេ? ដូចនៅវិទ្យាស្ថានសន្តប៉ូល យើងមាននិស្សិតដែលទទួលអាហារូបករណ៍ពីព្រះសហគមន៍ច្រើនណាស់ ប៉ុន្តែសព្វថ្ងៃគេជិះម៉ូតូទំនើបៗណាស់ ខ្ញុំបានប្រាប់ទៅថ្នាក់ដឹកនាំសាលាថានេះយើងគួមានកម្រិតដែរ។ យើងឃើញសង្គមយើងទាក់ទាញឲ្យមនុស្សចង់ទំនើបដូចគេ យូរៗធ្វើឲ្យយើងភ្លេចអ្វីដែលសំខាន់សម្រាប់ជិវិតរបស់យើង។ ថ្ងៃណាមួយលែងមានសេចក្តីសុខ លែងមានសុភមង្គលនៅក្នុងជីវិត ដោយសារគេយកអតិភាពគឺលុយ ដើម្បីធ្វើដូចគេ។ ហេតុនេះហើយ នៅពេលយើងដើរតាមធម្មទេសនារបស់ព្រះយេស៊ូដូចយើងបានស្តាប់ជិតបីអាទិត្យ ជាធម្មទេសនាដែលគ្រីស្តបរិស័ទត្រូវការលើឈើឆ្កាង។ ព្រះយេស៊ូណែនាំឲ្យយើងធ្វើខុសពីគេពេលមានសត្រូវយើងមិនស្អប់គេយើងស្រឡាញ់គេ ពេលគេសុំអ្វីពីយើងយើងខិតខំជួយគេ...។ ព្រះយេស៊ូណែនាំឲ្យយើងមិនទទួលសិរីរុងរឿងតាមលោកីយ៍ ប៉ុន្តែណែនាំឲ្យយើងទទួលសិរីរុងរឿងពីព្រះជាម្ចាស់។

អ្វីៗដែលយើងធ្វើ គឺយើងធ្វើនៅក្នុងភាពស្ងៀមស្ងាត់ ដើម្បីព្រះជាម្ចាស់ដឹងមនុស្សលោកមិនត្រូវការដឹងទេ។

យើងអធិដ្ឋាន ដើម្បីឲ្យយើងរស់នៅតាមអ្វីដែលព្រះយេស៊ូមានព្រះបន្ទូល អ្វីដែលកើតឡើងថ្ងៃស្អែកទុកឲ្យកើតឡើងប៉ុន្តែគិតអំពីថ្ងៃនេះ។ យើងទីពឹងលើព្រះជាម្ចាស់ ដោយសារយើងដឹងថាព្រះបិតាប្រទានអ្វីៗទាំងអស់ដែលយើងត្រូវការ។ អាម៉ែន៕